# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** : ០០១/២៥ **ក.ប**/ខ.ល

## សារលិខិតជូនពរ

**សូមគោរពជូន**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា**
**និងជាប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា**
**និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន ប្រធានកាកបាទក្រហមកម្ពុជា**

***ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត!***

ក្នុងឱកាសដ៏សិរីមង្គលាភិរម្យប្រសើរថ្លៃថ្លាប្រកបដោយទឹកចិត្តសោមនស្សរីករាយនៃខួបអាពាហ៍ពិពាហ៍គម្រប់ ៤៩ឆ្នាំ របស់ **សម្តេចអគ្គមហាសេនាបតីតេជោ** និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ជាទីគោរពដ៏ខ្ពង់ខ្ពស់ តាងនាមថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្នុងនាមខ្ញុំបាទ និងភរិយា ព្រមទាំងក្រុមគ្រួសារ សូមសម្តែងនូវសេចក្តីអំណរសាទរដ៏ស្មោះអស់ពីដួងចិត្ត និងសូមលើកហត្ថប្រណម្យបួងសួងគោរពជូនពរជ័យដល់ចំណងអាពាហ៍ពិពាហ៍របស់ **សម្តេចអគ្គមហាសេនាបតីតេជោ** និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** សូមបរិបូរណ៍ដោយភាពផ្អែមល្ហែមត្រជាក់ត្រជុំដូចជាទឹកអង្គបំពង់ខ្វី សុខសុភមង្គលជាអមតៈ និងសូមទទួលបាននូវសុខភាពល្អ កាយពលមាំមួន ទីឃាយុយឺនយូរ បញ្ញាញាណភ្លឺថ្លាវាងវៃ និងឈ្នះអស់ពោគាព្យាធិទាំងឡាយ ដើម្បីបន្តរួមចំណែកដឹកនាំមាតុភូមិកម្ពុជាឱ្យបោះជំហានទៅមុខកាន់តែរឹងមាំ សម្បូរសប្បាយ រុងរឿងថ្កុំថ្កើងក្រោមម្លប់សុខសន្តិភាពជានិច្ចនិរន្តរ៍តរៀងទៅ។

ឆ្លៀតក្នុងឱកាសអភិលក្ខិតកាលដ៏មហាមង្គលនេះ យើងខ្ញុំទាំងអស់គ្នា សូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ កែវទាំងបី និងវត្ថុស័ក្តិសិទ្ធិក្នុងលោក សូមជួយថែរក្សាអភិបាលប្រោះព្រំប្រសិទ្ធពរជ័យជូនដល់ **សម្តេចអគ្គមហាសេនាបតីតេជោ** និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ព្រមទាំងបុត្រា បុត្រី ចៅប្រុស ចៅស្រី ជាទីស្រឡាញ់ សូមសមប្រកបដោយព្រះពុទ្ធពរបួនប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា និងជាប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ** និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន ប្រធានកាកបាទក្រហមកម្ពុជា** មេត្តាទទួលនូវគារវកិច្ចភាពដ៏ស្មោះស្ម័គ្រ និងអភិវន្ទនកិច្ចដ៏ខ្ពង់ខ្ពស់បំផុតអំពីយើងខ្ញុំទាំងអស់គ្នា។

ថ្ងៃព្រហស្បតិ៍ ៤កើត ខែបុស្ស ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី២ ខែមករា ឆ្នាំ២០២៥

**តំណាងថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**រដ្ឋមន្ត្រី**

**ហេង សួរ**

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩